ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៨២៦/១៦-១០-២០០៦

សាលដីកា

លេខ:១១៨(ជ)/២៧-១២-២០០៧

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៧-១២-២០០៧ ដែលមានសមាសភាពដូចតទៅ៖

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted]

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៨២៦ ចុះថ្ងៃទី១៦-១០-២០០៦ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted]សំណាង ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន កើតនៅភូមិបឹងសង្កែ ឃុំបសែត ស្រុកបសែត ខេត្តកំពង់ស្ពឺ [redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន ។ ឃាត់ខ្លួនថ្ងៃទី២០.៩.២០០៦ ។ បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគារព្រៃស ម១ ។

២-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសឿន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររោងចក្រ កើតនៅភូមិកោះអន្លង់ចិន ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃ [redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ[redacted](រ) នៅលីវ ទោសពីមុនគ្មាន ។ ឃាត់ខ្លួនថ្ងៃទី២០.៩.២០០៦ ។

មេធាវីការពារឈ្មោះ [redacted] ស៊ីថាន់

២០០

ត្រូវចោទពីបទៈប្លន់(លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០០៥ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខហួង ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## ឯរឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី១៦.០១.២០០៦ របស់ឈ្មោះ [redacted] សុខហួង ពីបទៈលួចគ្រាប់ជ័រប្លាស្ទិចរបស់រោងចក្រ ដោយសំអាងហេតុថា កាលខែធ្នូ ឆ្នាំ២០០៥ ឈ្មោះ [redacted] ប៊ុនធឿន ហៅ មិត្រា និង [redacted] សំណាង ហៅ កា ជាកម្មករបំរើនៅរោងចក្រឃីហោ យៀកហោ បានឃុបឃិតជាមួយសន្តិសុខរោងចក្រលួចគ្រាប់ជ័រប្លាស្ទិចរបស់រោងចក្រ អស់ចំនួន៥៨បាវ ។ សំណូមពរសមត្ថកិច្ចបើកករណីដោះស្រាយជនពាក់ព័ន្ធទៅតាមផ្លូវច្បាប់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ១០៧(ឈ) ចុះថ្ងៃទី១៣-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទៈ

-ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅក្នុងរោងចក្រសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅក្នុងរោងចក្រសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ប្រាំមួយឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២០.០១.២០០៦ ពីបទៈប្លន់(លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០០៦ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] គុល ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិព្រែកថ្មី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ដាក់ពន្ធនាគារកំណត់មួយឆ្នាំកន្លះ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ពីបទៈទទួលផលចោរកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០០៥ តាមមាត្រា៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ តែទោសនេះត្រូវអនុវត្តព្យួរក្នុងរយៈពេលសាកល្បង៥ឆ្នាំ តាមមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-បង្គាប់ឲ្យជនជាប់ចោទសងថ្លៃជ័រចំនួន៤.០០០.០០០រៀល បើមិនព្រមសងត្រូវចាប់ដាក់គុកបង្ខំដល់រូបកាយ តាមច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៧០១

៤-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ[redacted]សំណាង, [redacted] ប៊ុនធឿន កំបាំងមុខជនជាប់ចោទ [redacted] ឌុល សម្រេចបើកផ្លូវប្ដឹងទាស់ រយៈពេល១៥ថ្ងៃ និង បណ្ដឹងឧទ្ធរណ៍រយៈពេលពីរខែ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី៣០-៥-២០០៧ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាសង្ខេបរឿង

-ជនជាប់ចោទឈ្មោះ[redacted] សំណាង (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន (វត្តមាន)

-មេធាវីលោក[redacted] ស៊ីថាន់ (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] សុខហ្វុង (អវត្តមាន)

-ឈ្មោះ[redacted] ប៊ុនធឿន អះអាងថាៈ ខ្លួនមិនបានស៊ីឈ្នោះគេនៅរោងចក្រទេ ។ ខ្លួនគ្មានចេតនាលាក់ឈ្មោះទេ ។ ខ្លួនបានប្ដឹងឧទ្ធរណ៍ ផ្ដិតមេដៃដាក់ឈ្មោះ [redacted] ប៊ុនធឿន ឈ្មោះក្រៅ មិត្រា ។ ខ្លួនសូមបដិសេធក្រោយមកខាងរោងចក្រឃើញខ្លួនធ្វើការល្អគេផ្លាស់ខ្លួនទៅរោងចក្រផ្សេង ។ ខ្លួនធ្វើការពីម៉ោងដប់យប់ដល់ម៉ោងបីទៀបភ្លឺ ។ ខ្លួនមិនលួចជាមួយគេទេ ខ្លួនជាប្រធានក្រុមចាក់ជ័រ ខ្លួនធ្វើការថ្ងៃ៤ម៉ោង និងយប់៤ម៉ោង ខ្លួនមិនស្គាល់ឈ្មោះ [redacted]ហ្វួត ទេ ។ ពេលនោះឈ្មោះ ហ្វួត ឲ្យប្រាក់៣០០០០រៀល គេយកប្រាក់ ។ ខ្លួនគ្រាន់តែបានឃើញគេលួចជ័រ ខ្លួនមិនបានបើកទ្វារឲ្យគេទេ ។ កម្មករធ្វើការពីយប់ទល់ភ្លឺ ខ្លួនឃើញគេដឹកជ័រចេញដែរ មួយយប់បីម៉ឺនឲ្យតែម្ដង ឈ្មោះ [redacted] ឌុល ជាអ្នកឲ្យ[redacted] ហ្វួត អត់ដែលឲ្យទេ ។ ខ្លួនបានទទួលលុយពី[redacted]ហ្វួត បីម៉ឺនរៀល និង ទទួលពី [redacted] ឌុល បីម៉ឺនដែរ ។ សំណូមពរសូមក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់រូបខ្លួន ដោយក្ដីអនុគ្រោះ ។

-តំណាងមហាអយ្យការសន្និដ្ឋានថាៈ រឿងក្ដីនេះជនជាប់ចោទបានសារភាពចំពោះមុខតុលាការអស់ហើយ ពិតប្រាកដមែន ។ សូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ១០៧(ឈ) ចុះថ្ងៃទី១៣-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

-មេធាវីលោក [redacted]នីនា សន្និដ្ឋានថាៈ តាមចម្លើយ កូនក្ដីខ្លួនពុំបានចូលរួមប្រព្រឹត្តលួចជ័រកៅស៊ូនោះទេ កំហុសគាត់គ្រាន់តែមិនបានរាយការណ៍ជូនសមត្ថកិច្ចប៉ុណ្ណោះ គាត់គ្រាន់តែបានទទួលប្រាក់ពីគេប៉ុណ្ណោះ សូមក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួន ។

-ក្រោយពីបានអានរបាយការណ៍

-ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ

២០៧

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា ៖

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧.៧.២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] ប៊ុនធឿន ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមបញ្ញត្តិមាត្រា១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

២-ពាក្យសុំការពារក្តី ចុះថ្ងៃទី១៥.១១.២០០៦ របស់មេធាវី [redacted] វណ្ណៈ ការពារជនជាប់ចោទ[redacted] ប៊ុនធឿន មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-លិខិតលេខៈ៧៩១ គម/០៧ ចុះថ្ងៃទី៧.១២.២០០៧ របស់គណៈមេធាវី ចាត់មេធាវី[redacted] ស៊ីថាន់ ការពារឲ្យជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៤-តាមចម្លើយឈ្មោះ[redacted] ប៊ុនធឿន ហៅ ចិត្រា នៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកប្រា បានឆ្លើយថាខ្លួនបានលួចដែររបស់រោងចក្រចំនួន២៦បារ នៅថ្ងៃទី២ មករា ឆ្នាំ២០០៦ មានគ្នា៤នាក់យកបាន១០បារ ក្រោយមកថ្ងៃមិនចាំយកបាន១០បារ ហើយថ្ងៃទី៦ មករា ឆ្នាំ២០០៦ យកបាន៦បារទៀត ។ ឃើញថាឈ្មោះ[redacted] ប៊ុនធឿន បានប្រព្រឹត្តបទប្លន់ ដូចការចោទប្រកាន់មែន ។

៥-តាមលិខិតបញ្ជាក់សុខភាព លេខៈ២៦៦ ចុះថ្ងៃទី២៥.៩.២០០៧ របស់មន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត បញ្ជាក់ថាឈ្មោះ[redacted] សុវណ្ណារ៉ាំ ([redacted] ប៊ុនធឿន) បានចូលទៅព្យាបាលជម្ងឺផ្លូវចិត្ត-សរសៃប្រសាទ កាលពីថ្ងៃ២២ សីហា ឆ្នាំ២០០៣ ដល់ ២ កញ្ញា ២០០៣ ឃើញថាជនជាប់ចោទពុំសូវមានសតិជានាល្អទេ ហើយព្យសនកម្មតិចតួចគប្បីពិចារណាបន្ធូរបន្ថយទោស ។

៦-សាលក្រមព្រហ្មទណ្ឌលេខៈ១០៧(ឈ) ចុះថ្ងៃទី១៣-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវគួរតម្កល់ទុកជាបានការ ដោយគ្រាន់តែកែប្រែទណ្ឌកម្មលើឈ្មោះ[redacted] ប៊ុនធឿន តាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧.៧.២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] ប៊ុនធឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ១០៧(ឈ) ចុះថ្ងៃទី១៣-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ដោយគ្រាន់តែកែប្រែការផ្តន្ទាទោសលើឈ្មោះ[redacted] ប៊ុនធឿន មកត្រឹមកំណត់ ៤ ឆ្នាំវិញ គិតពីថ្ងៃចាប់ខ្លួនថ្ងៃ១៧.០១.២០០៦ ចំណុចផ្សេងទៀតរក្សាទុកជាបានការដដែល ។

២០៣

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុន ធឿន មេធាវីការពារជនជាប់ចោទ និង កំបាំងមុខដើមបណ្ដឹង ។

បើកផ្លូវប្ដឹងតវ៉ា តាមកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខ[redacted] | ហត្ថលេខ[redacted], [redacted] | ហត្ថលេខា[redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ភ្នំពេញ,ថ្ងៃទី១៧ ខែ៧ ឆ្នាំ ២០១៤

ប្រធានសាលាឧទ្ធរណ៍

ក្រឡាបញ្ជី

[redacted]

[redacted]